# ការពន្លូតកូន

## ការពន្លូតកូន (ឬការបញ្ចប់មានផ្ទៃពោះ) កើតមានឡើងពេលណាមានផ្ទៃពោះត្រូវបានបញ្ចប់ដោយចេតនា

- ការពន្លូតកូនគឺជាការស្របច្បាប់នៅក្នុងរដ្ឋវិចថូរៀ។
- ការពន្លូតកូនមានពីរប្រភេទ៖ **ការវះកាត់** និង **ការប្រើថ្នាំពេទ្យ**។ ប្រភេទទាំងពីរមានសុវត្ថិភាព និងអាចទុកចិត្តបាន។
- នៅក្នុងរដ្ឋវិចថូរៀ អ្នកអាចមានការពន្លូតកូនដោយការប្រើថ្នាំពេទ្យរហូតដល់ប្រាំបួនសប្តាហ៍នៃការមានផ្ទៃពោះ('ការមានផ្ទៃពោះ')។ អ្នកអាចមានការពន្លូតកូនដោយការវះកាត់ ចាប់ពីប្រហែល៦សប្តាហ៍នៃការមានផ្ទៃពោះ។
- មានកន្លែងសុវត្ថិភាពដែលអាចចូលទៅរហូតដល់១៥០ម៉ែត្រ នៅជុំវិញតំបន់គ្លីនិកពន្លូតកូនក្នុងរដ្ឋវិចថូរៀ។ នេះមានន័យថា អ្នកអាចចូល ឬចាកចេញពីគ្លីនិកដោយគ្មាននរណាម្នាក់ព្យាយាមរំខានអ្នក។
- វេជ្ជបណ្ឌិតដែលមិនចង់ធ្វើការពន្លូតកូន ត្រូវបញ្ជូនអ្នកទៅឱ្យវេជ្ជបណ្ឌិតម្នាក់ទៀតដែលមិនជំទាស់នឹងការផ្តល់ព័ត៌មាន និងសេវាកម្មពន្លូតកូន។
- ផលវិបាកធ្ងន់ធ្ងរនៃការពន្លូតកូនគឺកម្រមានណាស់។ ប្រសិនបើអ្នកព្រួយបារម្ភអំពីសុខភាពរបស់អ្នកបន្ទាប់ពីការពន្លូតកូន សូមស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។
- ប្រសិនបើអ្នកគិតអំពីការពន្លូតកូន ហើយចង់បានព័ត៌មានអំពីការពន្លូតកូន និងសេវាកម្មដែលអាចរកបាននៅរដ្ឋវិចថូរៀ អ្នកអាចស្វែងរកនៅតាមវិបសែថ៍ 1800myoptions.org.au ឬហៅទូរស័ព្ទ 1800MyOptions លេខ 1800 696 784។

**ការប្រៀបធៀបការពន្លូតដោយប្រើថ្នាំពេទ្យ និងការវះកាត់**

| | ការពន្លូតកូនដោយប្រើថ្នាំពេទ្យ | ការពន្លូតកូនដោយការវះកាត់ |
|---|---|---|
| **តើនេះជានីតិវិធីប្រភេទណា?** | • មិនវះកាត់ ដែលស្រដៀងគ្នានឹងការរលូតកូន<br>• ត្រូវលេបថ្នាំគ្រាប់សម្រាប់នីតិវិធីនេះ | • នីតិវិធីវះកាត់ ជាធម្មតាជាមួយការចាក់ថ្នាំស្ពឹក |
| **តើវាមានប្រសិទ្ធភាពដូចម្តេចដែរ?** | • ទទួលបានជោគជ័យពី៩៥ ទៅ៩៨ភាគរយ<br>• ប្រហែលពីរ ទៅ ប្រាំភាគរយនៃស្ត្រី ត្រូវលេបថ្នាំគ្រាប់បន្ថែម ឬនីតិវិធីវះកាត់តូចមួយដើម្បីបញ្ចប់ការពន្លូតកូន | • ទទួលបានជោគជ័យ៩៨ភាគរយ |
| **តើមានសេវាកម្មសុខភាពអ្វីខ្លះដែលផ្តល់ឱ្យ?** | ពិនិត្យនៅតាមវិបសែថ៍ 1800MyOptions.org.au<br>ជម្រើសរួមមាន៖<br>• វេជ្ជបណ្ឌិតព្យាបាលពេទូទៅ<br>• សេវាកម្មសុខភាពសហគមន៍<br>• គ្លីនិកពន្លូតកូនឯកជន និងមន្ទីរពេទ្យ<br>• មន្ទីរពេទ្យសាធារណៈ<br>• តាមរយៈ 'telehealth' ដែលជាការពិគ្រោះយោបល់តាមទូរស័ព្ទ ដោយមានការធ្វើតេស្តបញ្ជាក់ពីការមានផ្ទៃពោះបានធ្វើឡើងនៅក្នុងតំបន់ | ពិនិត្យនៅតាមវិបសែថ៍ 1800MyOptions.org.au<br>ជម្រើសរួមមាន៖<br>• មន្ទីរពេទ្យសាធារណៈ<br>• មន្ទីរពេទ្យឯកជន<br>• គ្លីនិកឯកជនពេលថ្ងៃ |

VICTORIA State Government | Health and Human Services

| | ការពន្លូតកូនដោយប្រើថ្នាំពេទ្យ | ការពន្លូតកូនដោយការវះកាត់ |
|---|---|---|
| តើវាកើតមានឡើងនៅទីណា? | ការពិគ្រោះវេជ្ជសាស្ត្រគឺធ្វើនៅគ្លីនិក ឬតាមរយៈ telehealth (តាមទូរស័ព្ទ) ហើយការពន្លូតកូនកើតឡើងនៅផ្ទះ ឬនៅក្នុងស្ថានភាពដែលស្រដៀងគ្នា។ | នៅមន្ទីរពេទ្យ ឬមន្ទីរវះកាត់ពេលថ្ងៃ |
| តើវាត្រូវការរយៈពេលប៉ុន្មាន? | បន្ទាប់ពីការលេបថ្នាំគ្រាប់ទីមួយ ការលេបថ្នាំគ្រាប់លើកទីពីរត្រូវធ្វើឡើងក្នុងរយៈពេល២៤ ទៅ៤៨ម៉ោងក្រោយមក ហើយជាមធ្យមការពន្លូតកូននឹងកើតមានឡើងពីបួនទៅប្រាំមួយម៉ោង បន្ទាប់ពីពេលនោះមក | ជាធម្មតា រហូតដល់ទៅ១៥នាទីសម្រាប់នីតិវិធី បូកនឹងពេលរៀបចំ និងការងើបឡើងវិញដែលមានរយៈពេលពីរបីម៉ោង |
| តើការនេះកើតឡើងក្នុងដំណាក់កាលនៃការមានផ្ទៃពោះមួយណា? | ចាប់ពីពេលដែលការមានផ្ទៃពោះអាចត្រូវបានគេមើលឃើញនៅក្នុងអល់ត្រាសោន ហើយរហូតដល់ការមានផ្ទៃពោះ៩សប្តាហ៍ | មានសុវត្ថិភាពបំផុត ហើយជាទូទៅបំផុត គឺត្រូវធ្វើនៅចន្លោះ៦ និង១២សប្តាហ៍<br>មិនសូវមាន (ហើយមានសេវាកម្មតិចតួចផ្តល់ជូន) ក្នុងអំឡុងដំណាក់កាលក្រោយនៃការមានផ្ទៃពោះ |
| តើមានការហូរឈាមទេ? | ការហូរឈាមអាចមានរយៈពេលជាមធ្យមពី១០ ទៅ១៦ថ្ងៃ | ការហូរឈាមកើតមានខុសៗគ្នារវាងស្ត្រី ហើយអាចតិចឬធ្ងន់<br>វាអាចបន្តអស់រយៈពេលជាច្រើនសប្តាហ៍ ហើយមិនអាចទាយទុកបាន និងមិនទៀងទាត់ |
| តើវាអស់តម្លៃប៉ុន្មាន? | ទាក់ទងជាមួយអ្នកផ្តល់សេវាកម្ម សម្រាប់ព័ត៌មានអំពីការចំណាយ | ទាក់ទងជាមួយអ្នកផ្តល់សេវាកម្ម សម្រាប់ព័ត៌មានអំពីការចំណាយ |
| តើការពន្យាកំណើតអាចចាប់ផ្តើមនៅពេលណា? | ទម្រង់ភាគច្រើននៃការពន្យាកំណើតអាចចាប់ផ្តើមភ្លាមៗ ឬឆាប់បន្ទាប់ពីការពន្លូតកូនដោយប្រើថ្នាំ | ទម្រង់ភាគច្រើននៃការពន្យាកំណើតអាចចាប់ផ្តើមនៅថ្ងៃដូចគ្នានឹងការពន្លូតកូនដោយការវះកាត់ |

## ព័ត៌មានបន្ថែម

តារាងព័ត៌មាននេះគឺជាតារាងព័ត៌មានមួយក្នុងចំណោមតារាងព័ត៌មានបី អំពីការពន្លូតកូនដែលមានដាក់នៅក្នុងសៀវភៅ Health Translations Directory។ សូមមើលផងដែរ:

- នីតិវិធីពន្លូតកូន - ដោយការប្រើថ្នាំពេទ្យ
- នីតិវិធីពន្លូតកូន - ដោយការវះកាត់។

## កន្លែងដើម្បីទទួលបានជំនួយ

- 1800 my options ទូរស័ព្ទ 1800 696 784 អ្នកបកប្រែភាសា 131450
- វេជ្ជបណ្ឌិតរបស់អ្នក
- ផែនការគ្រួសារ វិចថូរៀ ទូរស័ព្ទ (03) 9257 0100 ឬការហៅឥតគិតថ្លៃ 1800 013 952
- សេវាកម្មសុខភាពសហគមន៍៖ https://www2.health.vic.gov.au/primary-and-community-health/community-health/community-health-directory
- ខ្សែទូរស័ព្ទជំនួយ ការមានផ្ទៃពោះ ការសម្រាលកូន និងទារក 1800 882 436

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។
© រដ្ឋវិចថូរៀ ក្រសួងសុខភាព និងសេវាកម្មមនុស្ស ខែមករា ឆ្នាំ២០១៩
អាចទទួលយកបាននៅតាមវិបសៃថ៍ <http://healthtranslations.vic.gov.au/>